**Declassified to Public**
**12 June 2020**

D351/4

**នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៤/២/០៧-០៩-២០០៩-អវតក-កសចស |
| ដាក់ទៅ | : | សហចៅក្រមស៊ើបអង្កេត |
| ថ្ងៃដាក់ | : | ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាជាតិ |
| ភាសាដើម | : | ខ្មែរ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18 / 08 / 2017
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សម្ងាត់**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ដីកាសន្និដ្ឋានស្ថាពរ**
**ទាក់ទងករណី អោ អាន អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង**

---

**អ្នកដាក់ឯកសារ**
សហព្រះរាជអាជ្ញាជាតិ
លោកស្រី ជា លាង

**អ្នកទទួលឯកសារ**
សហចៅក្រមស៊ើបអង្កេត
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Michael BOHLANDER

**ចម្លងជូន**

សហព្រះរាជអាជ្ញាអន្តរជាតិ
លោក Nicholas KOUMJIAN

មេធាវីការពារក្តី អោ អាន
លោក មុំ លុច្ប
លោក Richard ROGERS
លោក Goran SLUITER

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី
ជេត វណ្ណលី ផែន ពៅ
ហុង គីមសួន Laure DESFORGES
គីម ម៉េងឃី Isabelle DURAND
ឡោ ជុនធី Emmanuel JACOMY
សំ សុគង់ Martine JARQUIN
ស៊ិន ស៊ីវ៉ន Lyma NGUYEN
ទី ស្រីនណា Nushin SARKARATI

## ១. សេចក្តីផ្តើម

1. ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេត បានបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធានផ្ទៃក្នុង[1] ក្នុងគោលបំណងដើម្បីឱ្យសហព្រះរាជអាជ្ញា ចេញដីកាសន្និដ្ឋានស្ថាពរ។ យោងតាមវិធាន ៦៦(៥) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសម្អាងហេតុ ហើយត្រូវបញ្ជូនសំណុំរឿងត្រឡប់ទៅសហចៅក្រមស៊ើបអង្កេតវិញ។

## ២. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ បានពិភាក្សាគ្នាលើបញ្ហាខ្វែងយោបល់គ្នា អំពីការប្តឹងចោទជនសង្ស័យថ្មីបន្ថែមទៀតផ្សេងពីជនសង្ស័យដែលមានស្រាប់នៅ អ.វ.ត.ក ដើម្បីបញ្ជូនទៅសហចៅក្រមស៊ើបអង្កេត ឱ្យបើកការស៊ើបសួរ។ ក្នុងនោះ ជំហររបស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺមានបំណងដាក់ឱ្យបើកការស៊ើបអង្កេតលើជនសង្ស័យបន្ថែមសម្រាប់សំណុំរឿងលេខ ០០៣ និងលេខ ០០៤។ ចំណែកឯសហព្រះរាជអាជ្ញាជាតិមានជំហរមិនឯកភាពក្នុងការបើកឱ្យមានការស៊ើបអង្កេតលើជនសង្ស័យបន្ថែមផ្សេងពីជនសង្ស័យដែលមានស្រាប់នៃសំណុំរឿងលេខ ០០១ និងលេខ ០០២ នោះឡើយ[2]។

3. សហព្រះរាជអាជ្ញាអន្តរជាតិបានសម្រេចនាំយកករណីខ្វែងយោបល់គ្នានេះ ទៅចំពោះមុខអង្គបុរេជំនុំជម្រះ តាមរយៈអំណះអំណាងជាលាយលក្ខណ៍អក្សរ អំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨[3] បញ្ជូនទៅការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក។

---

[1] សំណុំរឿងលេខ ០០៤/២ ឯកសារលេខ D351 ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធានផ្ទៃក្នុង ៦៦(៤) ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ របស់សហចៅក្រមស៊ើបអង្កេត។

[2] កំណត់ហេតុ នៃការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិលើការចោទប្រកាន់ជនសង្ស័យថ្មីបន្ថែម ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨។

[3] អំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នាស្របតាមវិធាន ៧១.២។

នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៨ ការិយាល័យរដ្ឋបាលបានថតចម្លងឯកសារនេះ រួចបញ្ជូនមកសហព្រះរាជអាជ្ញាជាតិ ស្របតាមវិធាន ៧១.២ នៃវិធានផ្ទៃក្នុង[4]។

4. នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ អនុលោមតាមវិធាន៥៣ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាអន្តរជាតិ បានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ") ដែលក្នុងដីកានោះ គាត់បានចោទប្រកាន់ផងដែរថា អោ អាន ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩[5]។ បន្ទាប់មកសហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចោទប្រកាន់ អោ អាន ថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋដទៃទៀត[6]។

5. នៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាជាតិ បានដាក់ចម្លើយតបទៅនឹងអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នា[7] ជូនអង្គបុរេជំនុំជម្រះ ស្របតាមមាត្រា ២០ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក និងតាមវិធាន ៧១.២ នៃវិធានផ្ទៃក្នុង បន្ទាប់ពីអង្គបុរេជំនុំជម្រះបានយល់ព្រមតាមសំណើសុំពន្យារពេលក្នុងការដាក់ចម្លើយតបរួចមក។ ក្នុងចម្លើយតបនេះ សហព្រះរាជអាជ្ញាជាតិ បានលើកឡើងអំពីមូលហេតុនានា ដែលសហព្រះរាជអាជ្ញាជាតិមិនឯកភាពជាមួយនឹងដីកា

---

4 វិធាន ៧១.២ នៃវិធានផ្ទៃក្នុង។

5 សំណុំរឿង០០៤ ឯកសារD1 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០០៨។

6 សំណុំរឿង ០០៤/២ ឯកសារD65 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មតំបន់១ និងការធ្វើទុក្ខបុកម្នេញខ្មែរក្រោម ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១១។ សំណុំរឿង ០០៤/២ ឯកសារD191 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤។ សំណុំរឿង ០០៤/២ ឯកសារD254/1 ចម្លើយតបចំពោះដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទាក់ទងនឹងវត្តតាមាឃ ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥។ សំណុំរឿង០០៤/២ ឯកសារD272/1 ចម្លើយតប ចំពោះដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទាក់ទងនឹងវិសាលភាពនៃកិច្ចស៊ើបសួរ លើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅតំបន់១ និងតំបន់៤ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥។

7 ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ ទៅនឹងអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីហេតុការណ៍និងមូលហេតុនៃការខ្វែងយោបល់គ្នា ស្របតាមវិធាន ៧១.២ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៨។

សន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី (សំណុំរឿងលេខ ០០៣ និងលេខ ០០៤) របស់សហព្រះរាជអាជ្ញាអន្តរជាតិ។

6. នៅថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ អង្គបុរេជំនុំជម្រះបានចេញដីកាអញ្ជើញដល់សហព្រះរាជអាជ្ញាឲ្យដាក់ជូនសេចក្តីសន្និដ្ឋានបន្ថែមទៀតប្រសិនបើមាន ដែលពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីនៃករណីខ្វែងយោបល់គ្នា។[8]

7. សហព្រះរាជអាជ្ញាអន្តរជាតិ បានជូនដំណឹងដល់អង្គបុរេជំនុំជម្រះ កាលពីថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩ ថា "គាត់ពុំមានសេចក្តីសង្កេតបន្តទៀត ដែលជាការបន្ថែមទៅលើសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលមានរួចស្រេចហើយនៅក្នុងសេចក្តីសន្និដ្ឋានរបស់គាត់ដែលបានដាក់កាលពីថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ ២០០៨ នោះឡើយ"។[9] ចំណែកឯសហព្រះរាជអាជ្ញាជាតិ បានដាក់ឯកសារដែលទាក់ទងនឹងកិច្ចពិភាក្សារបស់រដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា និងកិច្ចពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ អំពីការបង្កើត អ.វ.ត.ក។

8. នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៩ អង្គបុរេជំនុំជម្រះ បានចេញសេចក្តីណែនាំឲ្យដាក់ឯកសារពិស្តារបន្ថែម និងដីកាកំណត់កាលបរិច្ឆេទសវនាការ ដល់សហព្រះរាជអាជ្ញាទាំងពីរ ដោយមានភ្ជាប់នូវសេចក្តីសង្កេត និងសំណួរមួយចំនួន ដើម្បីឲ្យសហព្រះរាជអាជ្ញាទាំងពីរឆ្លើយបំភ្លឺផងដែរ។[10]

9. សហព្រះរាជអាជ្ញាជាតិ បានដាក់ចម្លើយតបទៅនឹងសេចក្តីណែនាំឲ្យដាក់ឯកសារពិស្តារបន្ថែមរបស់អង្គបុរេជំនុំជម្រះ និងសេចក្តីសង្កេតបន្ថែម កាលពីថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៩[11] ដែលក្នុងនោះ សហព្រះរាជអាជ្ញាជាតិ បានប្រកាន់ជំហរថា គ្មានយុត្តាធិការបុគ្គលលើជនដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនឲ្យស៊ើបសួរថ្មី និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ។

---

[8] សេចក្តីអញ្ជើញសហព្រះរាជអាជ្ញាឲ្យដាក់សេចក្តីសន្និដ្ឋានបន្ថែម ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩ របស់អង្គបុរេជំនុំជម្រះ។

[9] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងការអញ្ជើញរបស់អង្គបុរេជំនុំជម្រះឲ្យដាក់សេចក្តីសន្និដ្ឋានបន្តទៀត ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩។

[10] សេចក្តីណែនាំឲ្យដាក់ឯកសារពិស្តារបន្ថែម និងដីកាកំណត់កាលបរិច្ឆេទសវនាការរបស់ អ.ប.ជ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩។

[11] ចម្លើយតបទៅនឹងសេចក្តីណែនាំឲ្យដាក់ឯកសារពិស្តារបន្ថែមរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩ និងសេចក្តីសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញាជាតិ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ (ឯកសារលេខ ១៧)។

មានន័យថាជនដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទាំងពីរខាងលើនេះ មិនមែនជា "មេដឹកនាំជាន់ខ្ពស់" និងមិនមែនជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នោះទេ។

10. អង្គបុរេជំនុំជម្រះ មិនទទួលបាននូវសម្លេងគាំទ្រពីចៅក្រមបួនរូបយ៉ាងតិច ដើម្បីធ្វើសេចក្ដីសម្រេចលើការខ្វែងយោបល់គ្នានោះទេ។[12]

11. អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា នៅពេលដែលអង្គបុរេជំនុំជម្រះ មិនអាចឈានដល់ការធ្វើសេចក្ដីសម្រេចលើការខ្វែងយោបល់គ្នាដែលបាននាំយកមកដោះស្រាយនៅចំពោះមុខខ្លួននោះ យោងតាមវិធាន ៧៥.១ នៃវិធានផ្ទៃក្នុង គឺមានន័យថា សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី ដើម្បីបើកកិច្ចស៊ើបសួរ ស្របតាមវិធាន ៥៣.១ នៃវិធានផ្ទៃក្នុង។[13]

12. ដោយអនុលោមតាមសេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ លើការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ស្របតាមវិធាន៧១ នៃវិធានផ្ទៃក្នុង[14] នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទីបានបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ពាក់ព័ន្ធនឹងសំណុំរឿងលេខ០០៣ និងលេខ ០០៤ ទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបើកកិច្ចស៊ើបសួរលើសំណុំរឿងទាំងពីរនេះ[15]។

13. នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានជូនដំណឹងអំពីការចោទប្រកាន់ប្រឆាំងនឹង អោ អាន អំពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទី១ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទី២ មានដូចខាងក្រោម៖

---

[12] ឯកសារលេខ D1/1.1 និង D1/1.3 ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ របស់អង្គបុរេជំនុំជម្រះ។

[13] ឯកសារលេខ D1/1.1 ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ របស់អង្គបុរេជំនុំជម្រះ។

[14] ឯកសារ D1/1.3 សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន៧១ នៃវិធានផ្ទៃក្នុង ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩។

[15] ឯកសារ D1/1 សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទីអំពីការដាក់ឯកសារស្ដីពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២ និងទី៣ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩។

-ការរំលោភបំពានលើមាត្រា២០៩ ២១០ ៥០០ ៥០១ ៥០៣ ៥០៤ ៥០៥ ៥០៦ ៥០៧ និងមាត្រា ៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ (អំពើមនុស្សឃាត ទារុណកម្ម និងការធ្វើទុក្ខបុកម្នេញលើសាសនា)

-ការរំលោភបំពានអនុសញ្ញាស្តីពីការទប់ស្កាត់ និងផ្តន្ទាទោសចំពោះអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (អំពើប្រល័យពូជសាសន៍លើខ្មែរក្រោម ចាម និងវៀតណាម)

-ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា និងអំពើអមនុស្សធម៌ដទៃទៀត) និង

-អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ (ការធ្វើមនុស្សឃាតដោយចេតនា ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព ការដកហូតសិទ្ធិ ឬការផ្លាស់ទី ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។[16]

14. ជាមួយគ្នានឹងការជូនដំណឹងអំពីការចោទប្រកាន់ខាងលើនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដាក់ អោ អាន ឱ្យស្ថិតក្រោមការពិនិត្យជាពិសេសក្នុងតួនាទីជាលេខាតំបន់ ៤១ និងអនុលេខាភូមិភាគកណ្តាល ដែលគាត់បានប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុងដែនដីកម្ពុជា នៅក្នុងរយៈកាលប្រហែលពីចុងឆ្នាំ ១៩៧៦ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ នូវបទល្មើសដូចជា៖

-ការរំលោភបំពានមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ (មនុស្សឃាតដោយចេតនា) មានចែង និងត្រូវផ្តន្ទាទោសតាមមាត្រា ៣(ថ្មី) និងមាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក

-ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងសាសនា ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត មានចែង និងត្រូវផ្តន្ទាទោសតាមមាត្រា ៥ និងមាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។[17]

---

[16] សំណុំរឿង ០០៤/២ ឯកសារ D242 កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ទំព័រទី ៦-៧ (ភាសាខ្មែរ)។

[17] សំណុំរឿង ០០៤/២ ឯកសារ D242 កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ ទំព័រទី ៩-១១ (ភាសាខ្មែរ)។

15. នៅក្នុងការដាក់ អោ អាន ឱ្យស្ថិតក្រោមការពិនិត្យនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានជូនដំណឹងថា គាត់អាចនឹងសម្រេចដាក់ អោ អាន ឱ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋបន្ថែមទៀត ដោយផ្អែកតាមការចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី១ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទី២ ប្រសិនបើមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់ បញ្ជាក់ថា អោ អាន អាចជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋបែបនោះ។[18]

16. ដោយមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា អោ អាន អាចទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តឡើងនៅភូមិភាគកណ្ដាល មកលើជនជាតិចាម នៅខេត្តកំពង់ចាម ទើបនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចោទប្រកាន់ អោ អាន ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងបទចោទបន្ថែមនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។[19]

17. នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេត បានចេញសេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន ដោយជូនដំណឹងភាគីថា មានពេល១៥ថ្ងៃ បន្ទាប់ពីសេចក្ដីជូនដំណឹងនេះ ដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែម និងបង្គាប់ឱ្យបំបែកកិច្ចដំណើរការនីតិវិធី អោ អាន ចេញពីសំណុំរឿង០០៤[20]។ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពន្យារកាលបរិច្ឆេទកំណត់ចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម រហូតដល់ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧[21]។

---

[18] សំណុំរឿង ០០៤/២ ឯកសារ D242 កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ ទំព័រ ១៣ (ភាសាខ្មែរ)។

[19] សំណុំរឿង ០០៤/២ ឯកសារD303 កំណត់ហេតុនៃការបង្ហាញខ្លួនម្ដងទៀត ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ទំព័រ៦(ភាសាខ្មែរ)។

[20] សំណុំរឿង០០៤/២ ឯកសារD334 សេចក្ដីជូនដំណឹងអំពីការបិទការស៊ើបសួរប្រឆាំង អោ អាន ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦។ សំណុំរឿង ០០៤/២ ឯកសារ D334/1 ដីកាសម្រេចបំបែកសំនុំរឿង អោ អាន ចេញពីសំណុំរឿង០០៤ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦។

[21] សំណុំរឿង ០០៤/២ ឯកសារD340/1 ដីកាសម្រេចលើសំណើរបស់ អោ អាន សុំពន្យារយៈពេលកំណត់ ដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែម ក្រោយពីមានការជូនដំណឹងអនុលោមតាមវិធាន៦៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦។

18. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ មេធាវីការពារក្តី អោ អានបានដាក់សំណើសុំដល់អង្គបុរេជំនុំជម្រះ សុំធ្វើមោឃភាពកំណត់ហេតុស្តាប់ចម្លើយមួយចំនួនរបស់អ្នកស៊ើបអង្កេតបីរូប នៃការិយាល័យសហចៅក្រមស៊ើបអង្កេត[22]។ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុញ្ញាតតាមសំណើសុំ និងបង្គាប់ឱ្យក្រឡាបញ្ជីបញ្ជូនសំណុំរឿង០០៤/២ ទៅអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន៧៦(៣) នៃវិធានផ្ទៃក្នុង[23]។ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ អង្គបុរេជំនុំជម្រះបានច្រានចោលសំណើសុំនេះ[24]។

19. នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦ មេធាវីការពារក្តី អោ អាន បានដាក់សំណើសុំឱ្យដាក់ឯកសារមួយចំនួនពាក់ព័ន្ធនឹង Henri Locard ទៅក្នុងសំណុំរឿង[25]។ សហព្រះរាជអាជ្ញា ពុំបានដាក់សារណាឆ្លើយតបទៅនឹងសំណើនេះទេ។

20. នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់ផែនទី និងឯកសារនៃសំណុំរឿង០០២ ទៅក្នុងសំណុំរឿង០០៤/២[26]។ មេធាវីការពារក្តីមិនបានដាក់សារណាតបនឹងសំណើនេះទេ។

21. នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ មេធាវីការពារក្តី បានដាក់សំណើបំពេញកិច្ចស៊ើបសួរលើកទី១៣ ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត ផ្តល់ជូនការវិភាគកំហុសមួយចំនួនដែលបានចោទនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ[27]។ សហព្រះរាជអាជ្ញា មិនបានដាក់សារណាឆ្លើយតបនឹងសំណើនេះទេ។

---

[22] សំណុំរឿង ០០៤/២ ឯកសារ D338 សំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកំនត់ហេតុស្តាប់ចម្លើយនានា របស់អ្នកស៊ើបអង្កេតចំនួនបីរូប ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦។

[23] សំណុំរឿង ០០៤/២ ឯកសារ D338/1 ដីកាសម្រេចលើសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកំណត់ហេតុស្តាប់ចម្លើយនានារបស់អ្នកស៊ើបអង្កេតចំនួនបីរូប ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧។

[24] សំណុំរឿង០០៤/២ ឯកសារ D338/2/5 ដីកាសម្រេចលើសំណើរបស់ អោ អាន សុំមោឃភាពកំណត់ហេតុស្តាប់ចម្លើយសាក្សី របស់អ្នកស៊ើបអង្កេតចំនួនបីរូប ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧។

[25] សំណុំរឿង០០៤/២ ឯកសារD339 សំណើសុំឱ្យដាក់ឯកសារមួយចំនួនពាក់ព័ន្ធនឹង Henri Locard ទៅក្នុងសំណុំរឿង ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦។

[26] សំណុំរឿង០០៤/២ ឯកសារ D342 សមណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់ផែនទី និងឯកសារនៃសំណុំរឿង០០២ ទៅក្នុងសំណុំរឿង០០៤/២ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦។

[27] សំណុំរឿង០០៤/២ ឯកសារ 345 សមណើសុំបំពេញកិច្ចស៊ើបសួរលើកទី១៣ របស់ អោ អាន ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧។

22. នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញសេចក្តីសម្រេចលើ *សំណើសុំឱ្យដាក់ឯកសារមួយចំនួនពាក់ព័ន្ធនឹង Henri Locard ទៅក្នុងសំណុំរឿង* និងសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់ផែនទី និងឯកសារនៃសំណុំរឿង០០២ ទៅក្នុងសំណុំរឿង០០៤/២[28]។

23. នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេត បានចេញដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១៣ របស់ អោ អាន[29]។

24. នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេត បានចេញសេចក្តីជូនដំណឹងលើកទី២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន ហើយបានជូនដំណឹងដល់ភាគីថា នឹងមិនអនុញ្ញាតផ្តល់ពេលវេលាបន្ថែម សម្រាប់សំនើសុំបំពេញកិច្ចស៊ើបសួរឡើយ បន្ទាប់ពីចេញសេចក្តីជូនដំណឹងលើកទី២នេះ ដោយសារតែវិធានផ្ទៃក្នុងមិនមានចែងតម្រូវបែបនេះ[30]។

25. នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧ មេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ប្រឆាំងការជូនដំណឹងមុនរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីការបកស្រាយលើ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋ ឬរបបនោះ[31]។

---

[28] សំណុំរឿង០០៤/២ ឯកសារ D339/1 ដីកាសម្រេចលើសមនើសុំដាក់ឯកសារមួយចំនួនពាក់ព័ន្ធនឹង Henri Locard ទៅក្នុងសំណុំរឿង ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦។ សំណុំរឿង០០៤/២ ឯកសារ D342/1 ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់ផែនទី និងឯកសារនៃសំណុំរឿង០០២ ទៅក្នុងសំណុំរឿង០០៤/២ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦។

[29] សំណុំរឿង ០០៤/២ ឯកសារ D345/1 ដីកាសម្រេចលើសំណើសុំបំបេញកិច្ចស៊ើបសួរលើកទី១៣ របស់ អោ អាន ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧។

[30] សំណុំរឿង០០៤/២ ឯកសារ D334/2 សេចក្តីជូនដំនឹងលើកទី២ អំពីការបិទការស៊ើបសួរប្រឆាំង អោ អាន ថ្ងៃតី ២៩ ខែមីនា ឆ្នាំ២០១៧។

[31] សំណុំរឿង ០០៤/២ ឯកសារ D347.1 ការជូនដំណឹងស្តីពីការបកស្រាយលើ"ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធរបស់របបឬរដ្ឋនោះ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧។ សំណុំរឿង ០០៤/២ ឯកសារ D347.1/3 បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស្តីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់របបនោះ ឬរដ្ឋនោះ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧។

26. នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៧ មេធាវីការពារក្តីបានដាក់សំណើដល់អង្គបុរេជំនុំជម្រះសុំធ្វើមោឃកិច្ចស៊ើបសួរទាំងស្រុង ឬផ្អាកកិច្ចស៊ើបសួររហូតដល់ពេលដែលមេធាវីការពារក្តី អាចអនុវត្តកិច្ចស៊ើបសួរដោយខ្លួនឯង និងសុំដាក់ពាក្យឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួររបស់ខ្លួន[32]។ នៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបដិសេធសំណើសុំមោឃភាព[33]។ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ មេធាវីការពារក្តីបានដាក់ការជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើសុំមោឃភាព[34]។

## ៣. ច្បាប់ជាធរមាន

27. ច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក តម្រូវឱ្យតុលាការនេះ *ធ្វើការវិនិច្ឆ័យទោស និងជំនុំជម្រះលើមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់កម្ពុជាដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុញ្ញាអន្តរជាតិដែលកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩*។[35]

## ៤. សេចក្តីសន្និដ្ឋាន និងអំណះអំណាង

28. សហព្រះរាជអាជ្ញាជាតិ ប្រកាន់នូវជំហរថា ជនត្រូវចោទទាំងអស់ដែលមានឈ្មោះក្នុងសំណុំរឿងលេខ ០០៤ ជាពិសេស អោ អាន (សំណុំរឿងលេខ ០០៤/២) មិនមែនជា ***មេដឹកនាំជាន់ខ្ពស់*** និង

[32] សំណុំរឿង ០០៤/២ ឯកសារ D350 សំនើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរ ថ្ងៃតី០៣ ខែឧសភា ឆ្នាំ២០១៧។

[33] សំណុំរឿង ០០៤/២ ឯកសារ D350/1 ដីកាសម្រេចលើសំណើរបស់ អោ អាន សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៧។

[34] សំណុំរឿង ០០៤/២ ឯកសារ D350/1/1 កាជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ អោ អាន សុំធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ ថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១៧។

[35] មាត្រា ១ និងមាត្រា២ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក, និងមាត្រា ១ នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។

មិនមែនជា ***ជនដែលទទួលខុសត្រូវខ្ពស់បំផុត*** *ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ ការរំលោភទៅច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ០៦ មករា ១៩៧៩* ពោលគឺមិនស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ។[36] ដូច្នេះសហព្រះរាជអាជ្ញាជាតិ សូមរក្សាឯកសារដែលបានដាក់ជូន ដូចមាននៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ និងថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ ដដែល។[37]

29. យោងតាមច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក[38] និងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ (កិច្ចព្រមព្រៀង)[39] បានកំណត់យ៉ាងច្បាស់អំពីគោលបំណងនៃការបង្កើតសាលាក្តីនេះ គឺដើម្បីវិនិច្ឆ័យទោសតែទៅលើ "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក តែប៉ុណ្ណោះ។

30. ការណ៍នេះបង្ហាញឱ្យឃើញថា ច្បាប់ អ.វ.ត.ក និង កិច្ចព្រមព្រៀង បានចង្អុលបង្ហាញអំពីតួនាទីរបស់ជនសង្ស័យដែលនឹងត្រូវយកមកធ្វើការវិនិច្ឆ័យទោស គឺមានតែពីរប្រភេទដូចបញ្ជាក់ខាងលើនេះ។ ចំណែកតួនាទីរបស់ជនត្រូវចោទ អោ អាន មិនមែនជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង មិនមែនជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ដែលត្រូវយកមកវិនិច្ឆ័យសេចក្តីនៅ អ.វ.ត.ក នេះទេ។

---

[36] ដូចមានរៀបរាប់នៅក្នុងឯកសារលេខ 7 ស្តីពី ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នាស្របតាមវិធាន ៧១.២ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ និងឯកសារលេខ 17 ស្តីពីចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំឱ្យដាក់ឯកសារពិស្តារបន្ថែមរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២៤ មេសា ២០០៩ និងសេចក្តីសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញាជាតិ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩។

[37] ឯកសារលេខ 7 ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ និងឯកសារលេខ 17 ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ ដដែលដូចខាងលើ។

[38] មាត្រា ១ នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក។

[39] មាត្រា ១ នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។

31. សូមធ្វើការកត់សម្គាល់ថា សហព្រះរាជអាជ្ញាទាំងពីរ បានយល់ស្រប និងឯកភាពគ្នា ក្នុងការជ្រើសរើសជនសង្ស័យចំនួនប្រាំរូប[40] ដើម្បីធ្វើការចោទប្រកាន់ដាក់ជូនសហចៅក្រមស៊ើបអង្កេត គឺដោយសារជនសង្ស័យទាំងនេះ ត្រូវបានសហព្រះរាជអាជ្ញា កំណត់ថាជា "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ"[41] និងជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក។

32. ការកំណត់ជនសង្ស័យប្រាំរូបខាងលើនេះ ដោយសហព្រះរាជអាជ្ញាជាតិ យល់ឃើញថា៖

**នួន ជា:** គឺជាអនុលេខាបក្សនៃបក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក), ជាសមាជិកអចិន្ត្រៃយ៍ ប.ក.ក និងជាប្រធានសភាតំណាងប្រជាជន នៃរបបកម្ពុជាប្រជាធិបតេយ្យ និងមានតួនាទីជាច្រើនផ្សេងទៀត។[42]

**អៀង សារី:** គឺជាសមាជិកអចិន្ត្រៃយ៍ ប.ក.ក, ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងមានតួនាទីផ្សេងទៀត។[43]

**ខៀវ សំផន:** គឺជាប្រធានគណប្រធានរដ្ឋ និងជាសមាជិកគណកម្មាធិការមជ្ឈិម ប.ក.ក និងមានតួនាទីផ្សេងទៀត។[44]

**អៀងធីរិទ្ធ:** គឺជាសមាជិកមជ្ឈិមបក្ស នៃ ប.ក.ក និងជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងមានតួនាទីផ្សេងទៀត។[45]

**កាំង ហ្គេកអ៊ាវ ហៅ ឌុច:** គឺជាប្រធានមន្ទីរសន្តិសុខ ស.២១ ដែលជាមន្ទីរសន្តិសុខ ដែលមានលក្ខណៈពិសេសជាងគេ និងមានភារកិច្ចផ្សេងទៀត។[46]

---

[40] នួន ជា, ខៀវ សំផន, អៀង សារី, អៀង ធីរិទ្ធ, និង កាំង ហ្គេកអ៊ាវ ហៅ ឌុច។

[41] មានបញ្ជាក់ជូនក្នុងឯកសារលេខ 17 ស្តីពី "ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំឱ្យដាក់ឯកសារពិស្តារបន្ថែមរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី២៤ មេសា ២០០៩ និងសេចក្តីសង្ខេបបន្ថែមរបស់សហព្រះរាជអាជ្ញាជាតិ, កថាខណ្ឌទី៥២, ត្រង់ ERN 00329369 (ភាសាខ្មែរ)។

[42] មានបញ្ជាក់ជូនក្នុងឯកសារលេខ 17 ស្តីពី "ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំឱ្យដាក់ឯកសារពិស្តារបន្ថែមរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី២៤ មេសា ២០០៩ និងសេចក្តីសង្ខេបបន្ថែមរបស់សហព្រះរាជអាជ្ញាជាតិ, កថាខណ្ឌទី៤០, ត្រង់ ERN 00329360 (ភាសាខ្មែរ)។

[43] ឯកសារលេខ 17 ដូចខាងលើ, កថាខណ្ឌទី៤០, ត្រង់ ERN 00329360-61 (ភាសាខ្មែរ)។

[44] ឯកសារលេខ 17 ដូចខាងលើ, កថាខណ្ឌទី៤០, ត្រង់ ERN 00329361-62 (ភាសាខ្មែរ)។

[45] ឯកសារលេខ 17 ដូចខាងលើ, កថាខណ្ឌទី៤០, ត្រង់ ERN 00329362-65 (ភាសាខ្មែរ)។

33. ចំណែកឯ **អោ អាន** ដែលមានឈ្មោះក្នុងសំណុំរឿងនេះ សហព្រះរាជអាជ្ញាជាតិ យល់ឃើញថា មិនស្ថិតក្នុងតួនាទីជា "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ" និងមិនមែនជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ។[47]

34. យោងតាមគោលការណ៍ច្បាប់ព្រហ្មទណ្ឌទូទៅ គឺបណ្តឹងអាជ្ញាតម្រូវឱ្យមានការអនុវត្តចំពោះគ្រប់បុគ្គលទាំងអស់។ ចំពោះច្បាប់ អ.វ.ត.ក និង កិច្ចព្រមព្រៀង គឺមានលក្ខណៈពិសេសខុសពីច្បាប់ទូទៅ ដោយហេតុថា ច្បាប់នេះតម្រូវឱ្យធ្វើការវិនិច្ឆ័យទោសតែលើជនពីរប្រភេទ[48] ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក មានន័យថា ច្បាប់ អ.វ.ត.ក និង កិច្ចព្រមព្រៀង គឺមានគោលបំណងធ្វើការកាត់សេចក្តីដោយផ្សារភ្ជាប់ទៅនឹងការផ្សះផ្សារបង្រួបបង្រួមជាតិ និងជាពិសេសដើម្បីទុកជាកេរ្តិ៍ដំណែលឱ្យអ្នកជំនាន់ក្រោយបានដឹងអំពីព្រឹត្តិការណ៍ជូរចត់ និងសាហាវយង់ឃ្នងនៃរបបកម្ពុជាប្រជាធិបតេយ្យ។

35. បើពិនិត្យទៅលើឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា មិនមែនមានតែក្នុងអំឡុងយុត្តាធិការរបស់ អ.វ.ត.ក ទេ គឺមានតាំងពីសម័យរបបសាធារណរដ្ឋខ្មែរ ដែលដឹកនាំដោយសេនាប្រមុខ លន់ ណុល មកម្ល៉េះ។ ក្នុងរបបសាធារណរដ្ឋខ្មែរ ក៏មានការទម្លាក់គ្រាប់បែកយ៉ាងច្រើនសន្ធឹកសន្ធាប់ និងបានបណ្តាលឱ្យស្លាប់មនុស្សស្លាប់ ពិការភាព និងបណ្តាលឱ្យទ្រព្យសម្បត្តិ ផ្ទះសម្បែងប្រជាជនត្រូវខូចខាតយ៉ាងដំណំជាច្រើនកន្លែងផងដែរ។[49] ដូច្នេះការកំណត់របស់ច្បាប់ អ.វ.ត.ក និង កិច្ចព្រមព្រៀង មិនបានបំពេញទៅតាមលក្ខខណ្ឌនៃច្បាប់ព្រហ្មទណ្ឌទេ។

36. ទោះបីជាមានការចោទប្រកាន់ជនត្រូវចោទរូបនេះក៏ដោយ ក៏មិនអាចបំពេញយុត្តិធម៌ឱ្យបានពេញលេញបានដែរ ហើយវាក៏មិនបានពង្រីកសមត្ថភាពរបស់ អ.វ.ត.ក ក្នុងការកត់ត្រាប្រវត្តិសាស្ត្ររបស់កម្ពុជាប្រជាធិបតេយ្យ និងមិនបានបង្កើនយុត្តិធម៌ដល់ជនរងគ្រោះដែរ ដោយហេតុថា អ្នកដែលបានប្រព្រឹត្តបទឧក្រិដ្ឋជាច្រើនទៀតក៏យើង មិនបានយកមកផ្តន្ទាទោសដែរ។

---

[46] ឯកសារលេខ 17 ដូចខាងលើ, កថាខណ្ឌទី៤០, ត្រង់ ERN 00329365-66 (ភាសាខ្មែរ)។

[47] ឯកសារលេខ 17 ដូចខាងលើ, កថាខណ្ឌទី៤០, ត្រង់ ERN 00329366 (ភាសាខ្មែរ)។

[48] មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

[49] ទស្សនាវដ្ដីស្វែងរកការពិតលេខ ៣ ចុះខែមិថុនា ឆ្នាំ២០០០ ទំព័រទី៩។

37. ដូច្នេះ សហព្រះរាជអាជ្ញាជាតិ ប្រកាន់យកការផ្សារភ្ជាប់ទៅនឹងបុព្វកថានៃកិច្ចព្រមព្រៀង ដែលតម្រូវឱ្យ សហព្រះរាជអាជ្ញា គិតគូរដល់ការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខមុននឹងធ្វើការប្ដឹងចោទប្រកាន់។[50] លើសពីនេះទៀត សហព្រះរាជអាជ្ញាជាតិ ក៏នៅតែរក្សាជំហរដូចមាននៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ និងថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ ដដែល ជាពិសេស គោលការណ៍យុត្តិធម៌ និងការផ្សះផ្សារបង្រួបបង្រួមជាតិ[51] គោលបំណងរបស់ច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង[52] នីតិវិធីអនុវត្ត[53] ការស៊ើបអង្កេតបឋម[54] និងការចោទប្រកាន់បែបសម្រិតសម្រាំងដែលជាយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិមួយចំនួន[55] ជាដើម។

38. ដូច្នេះឃើញថា លទ្ធផលតាំងពីដំបូងនៃការស៊ើបសួរបឋមដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ និងរហូតដល់ការបិទកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញាជាតិ យល់ឃើញថា ជនត្រូវចោទ អោ អាន មិនស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ ដោយហេតុថា ជនត្រូវចោទនេះ **មិនមែនជាមេដឹកនាំជាន់ខ្ពស់** និង **មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុត** ដែលត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដូចមានចែងក្នុងច្បាប់ អ.វ.ត.ក ទេ។[56]

39. ថ្វីត្បិតតែការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញាអំពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីនិងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម មិនអាចរកសម្លេងបានគ្រប់គ្រាន់នៅដំណាក់កាលអង្គបុរេជំនុំជម្រះ ដែលបានតម្រូវឱ្យមានការស៊ើបសួររហូតមកដល់ដំណាក់កាលនេះក៏ដោយ ក៏សហព្រះរាជអាជ្ញាជាតិ នៅតែយល់ឃើញថា ជនជាប់ចោទដែលមានឈ្មោះនៅក្នុងសំណុំរឿងនេះ មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ។

---

[50] កថាខ័ណ្ឌទី ២ នៃបុព្វកថា នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។

[51] ឯកសារលេខ 7 ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨, កថាខណ្ឌទី៨, ៩, ១០, ១១, ១៤, ១៥ ត្រង់ ERN 00267949-53 (ភាសាខ្មែរ)។

[52] ឯកសារលេខ 7 ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨, កថាខណ្ឌទី៤២ ដល់ ៤៩, ត្រង់ ERN 00267963-66 (ភាសាខ្មែរ)។

[53] ឯកសារលេខ 7 ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨, កថាខណ្ឌទី៥០ ដល់ ៥៤, ត្រង់ ERN 00267966-68 (ភាសាខ្មែរ)។

[54] ឯកសារលេខ 17 ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩, កថាខណ្ឌទី១៨, ១៩, ២០, ២១, ២២, ៣២, ត្រង់ ERN 00329352-57 (ភាសាខ្មែរ)។

[55] ឯកសារលេខ 7 ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨, កថាខណ្ឌទី២៤ ដល់ ៤១, ត្រង់ ERN 00267956-63 (ភាសាខ្មែរ)។

[56] ដូចមានបញ្ជាក់ជូននៅក្នុងឯកសារលេខ 7 ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ និងឯកសារលេខ 17 ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០០៩ ដូចខាងលើ។

## ៥. សំណើ

40. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាជាតិ សូមដាក់ជូនសំណុំរឿងលេខ ០០៤/២ នេះ ទៅសហចៅក្រមស៊ើបអង្កេត និងស្នើឲ្យសហចៅក្រមស៊ើបអង្កេតសម្រេចលើកលែងចោទប្រកាន់ប្រឆាំង **អោ អាន** តាមវិធាន ៦៧(៣)(ក) នៃវិធានផ្ទៃក្នុង។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | |